ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៤៣ សហវ.អ៣២

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យខេត្តប៉ៃលិន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៤៩៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធ លើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តប៉ៃលិន

## សម្រេច

**ប្រការ ១.-**

បង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តប៉ៃលិនដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម អៀង ខុង | អភិបាលរងនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. លោក ហុក សុផល | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៣. លោក អ៊ុក សារិន | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. លោក រាម សុមាន | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៥. លោក ផាន់ ពេជ្រ | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ៦. លោក យឹម ឡាំង | អភិបាលនៃគណៈអភិបាលស្រុកសាលាក្រៅ | សមាជិក |
| ៧. លោក សួស ស៊ីយ៉ាត | អភិបាលនៃគណៈអភិបាលក្រុងប៉ៃលិន | សមាជិក |
| ៨. លោក រស់ ធឿន | នាយទីចាត់ការអន្តរវិស័យខេត្ត | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់នៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ
- ក្នុងករណីចាំបាច់ អនុគណៈកម្មការនេះអាចបង្កើតក្រុមការងារជាជំនួយការផ្ទាល់បន្ថែមទៀតនៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ សម្រាប់ធ្វើការសម្របសម្រួលក្រុមការងារថ្នាក់ឃុំ-សង្កាត់ ។

ប្រការ ៣.-

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យ ឃុំ-សង្កាត់ ជាជំនួយការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម :

- រួមសហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត
- ចូលរួមកំណត់អចលនទ្រព្យតាមតំបន់ ប្រភេទ និងទីតាំង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសេចក្តីណែនាំរបស់គណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ចូលរួមផ្សព្វផ្សាយ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ជួយសហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យដល់រដ្ឋបាលសារពើពន្ធ
- ជួយសហការការងារផ្សេងទៀតជាមួយរដ្ឋបាលសារពើពន្ធតាមការស្នើសុំ
- សមាជិកក្រុមការងារ ត្រូវចូលរួមធ្វើការ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៤.-

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.-

ឯកឧត្តម លោក-លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ**
**សម្រាប់ពន្ធលើអចលនទ្រព្យ**

**គង់ វិបុល**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលាខេត្តប៉ៃលិន

  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៤ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ